ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ថ្ងៃអង្គារ ១៥កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០

## ប្រតិទិននៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២០ (វិសោធនកម្ម)

| ល.រ | ភារកិច្ចត្រូវបំពេញ | កាលបរិច្ឆេទ |
|---|---|---|
| ១ | ការចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ និងអ្នកសារព័ត៌មានជាតិ | ថ្ងៃទី០១ខែកញ្ញា - ២១ខែធ្នូ ឆ្នាំ២០២០ |
| ២ | ការចុះឈ្មោះអ្នកសង្កេតការណ៍អន្តរជាតិ និងអ្នកសារព័ត៌មានអន្តរជាតិ | ថ្ងៃទី០១ខែកញ្ញា - ២៨ខែធ្នូ ឆ្នាំ២០២០ |
| ៣ | ការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ | ថ្ងៃទី២៨ខែកញ្ញា - ២១ខែធ្នូ ឆ្នាំ២០២០ |
| ៤ | ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យចុះឈ្មោះ និងការិយាល័យបោះឆ្នោត | ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ |
| ៥ | ការបិទផ្សាយបញ្ជីបោះឆ្នោតចុងក្រោយ និងបង្ហោះលើគេហទំព័ររបស់ គ.ជ.ប (voterlist.nec.gov.kh) (App-Voterlist KH) | ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ |
| ៦ | ការចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ | ថ្ងៃទី០១ខែតុលា ឆ្នាំ២០២០ |
| ៧ | ការបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ | ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ |
| ៨ | ការប្តឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោតទៅក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ៣ថ្ងៃ | ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០(ថ្ងៃចុងក្រោយ) |
| ៩ | ការដោះស្រាយពាក្យបណ្តឹងតវ៉ាដោយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ៣ថ្ងៃ | ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២០(ថ្ងៃចុងក្រោយ) |
| ១០ | ការប្តឹងតវ៉ានឹងការបដិសេធរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទៅ គ.ជ.ប ក្នុងរយៈពេល ៥ថ្ងៃ | ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ (ថ្ងៃចុងក្រោយ) |
| ១១ | ការដោះស្រាយពាក្យបណ្តឹងតវ៉ាដោយ គ.ជ.ប ក្នុងរយៈពេល ៥ថ្ងៃ | ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២០(ថ្ងៃចុងក្រោយ) |
| ១២ | ការប្តឹងតវ៉ានឹងការបដិសេធរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ថ្ងៃ | ថ្ងៃទី១៤ខែវិច្ឆិកា ឆ្នាំ២០២០(ថ្ងៃចុងក្រោយ) |
| ១៣ | ការដោះស្រាយពាក្យបណ្តឹងតវ៉ាដោយក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០(ថ្ងៃចុងក្រោយ) |
| ១៤ | ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ទូទាំងប្រទេស | ថ្ងៃទី២៧ខែវិច្ឆិកា ឆ្នាំ២០២០ |
| ១៥ | ការប្តឹងតវ៉ា ឬជំទាស់លើបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ទៅក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ៥ថ្ងៃ | ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០(ថ្ងៃចុងក្រោយ) |
| ១៦ | ការដោះស្រាយពាក្យបណ្តឹងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ៣ថ្ងៃ | ថ្ងៃទី០៥ខែធ្នូ ឆ្នាំ២០២០(ថ្ងៃចុងក្រោយ) |
| ១៧ | ការប្តឹងតវ៉ា ឬជំទាស់នឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ទៅ គ.ជ.ប ក្នុងរយៈពេល ៥ថ្ងៃ | ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ (ថ្ងៃចុងក្រោយ) |
| ១៨ | ការដោះស្រាយពាក្យបណ្តឹងដោយ គ.ជ.ប ក្នុងរយៈពេល ៥ថ្ងៃ | ថ្ងៃទី១៥ខែធ្នូ ឆ្នាំ២០២០ (ថ្ងៃចុងក្រោយ) |
| ១៩ | ការប្តឹងតវ៉ា ឬជំទាស់នឹងសេចក្តីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ថ្ងៃ | ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០(ថ្ងៃចុងក្រោយ) |
| ២០ | ការដោះស្រាយពាក្យបណ្តឹងដោយក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០(ថ្ងៃចុងក្រោយ) |
| ២១ | ការផ្តល់សុពលភាព និងប្រកាសផ្សាយបញ្ជីបោះឆ្នោតផ្លូវការដោយ គ.ជ.ប | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ |

គ.ជ.ប








# សៀវភៅ
# សម្រាប់
# អ្នកចុះឈ្មោះបោះឆ្នោត

## ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២០
## ចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០

## ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២០




ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២០ មានគោលដៅធានាឱ្យបញ្ជីបោះឆ្នោតមានភាពពេញលេញ ភាពត្រឹមត្រូវ និងមានបច្ចុប្បន្នភាពប្រកបដោយសុវត្ថិភាពតាមរយៈ៖

– ការស្រង់ និងលុបឈ្មោះអ្នកបោះឆ្នោត ៖
- ដែលបានទទួលមរណភាព
- ដែលត្រូវបានដកហូតសិទ្ធិបោះឆ្នោតជាបណ្តោះអាសន្ន
- ដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេង

ដោយមានឯកសារជាសំអាងត្រឹមត្រូវ និងច្បាស់លាស់ ដើម្បីលុបចេញពីបញ្ជីបោះឆ្នោត ។



– ការកែតម្រូវឈ្មោះ ឬទិន្នន័យអ្នកបោះឆ្នោត តាមសំណើរបស់សាមីខ្លួនដោយផ្អែកលើឯកសារសំអាងត្រឹមត្រូវ ។

– ការចុះឈ្មោះបោះឆ្នោត សំដៅលើ ៖
- ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិបោះឆ្នោត ហើយមិនទាន់បានចុះឈ្មោះបោះឆ្នោតពីមុនមក
- ប្រជាពលរដ្ឋខ្មែរដែលមានអាយុ ១៨ឆ្នាំឡើង (អ្នកកើតមុន ឬកើតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០០៣)
- ប្រជាពលរដ្ឋខ្មែរដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលក្នុងឃុំ សង្កាត់ថ្មី

ត្រូវទៅចុះឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត ។

## រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និង ការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២០




ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២០ មានរយៈពេល **១៩ថ្ងៃ** ដែលប្រព្រឹត្តទៅចាប់ពី**ថ្ងៃទី១ ដល់ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០** នៅតាមសាលាឃុំ សង្កាត់ និងនៅតាមភូមិមួយចំនួនក្នុងឃុំ សង្កាត់ទូទាំងប្រទេស ។

ការិយាល័យចុះឈ្មោះបោះឆ្នោតបើកធ្វើការជារៀងរាល់ថ្ងៃ ទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យ ៖

- ពេលព្រឹកចាប់ពីម៉ោង ៧:០០ នាទីព្រឹក ដល់ម៉ោង ១១:៣០ នាទីថ្ងៃត្រង់ ។
- ពេលរសៀលចាប់ពីម៉ោង ២:០០ នាទីរសៀល ដល់ម៉ោង ៥:៣០ នាទីល្ងាច ។

ការិយាល័យចុះឈ្មោះបោះឆ្នោត **ត្រូវបិទ១ថ្ងៃ នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០** ដើម្បីបើកកិច្ចប្រជុំត្រួតពិនិត្យការអនុវត្តការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ។



## លក្ខខណ្ឌចុះឈ្មោះបោះឆ្នោត




ដើម្បីចុះឈ្មោះបោះឆ្នោតនៅក្នុងការិយាល័យណាមួយក្នុងឃុំ សង្កាត់ ប្រជាពលរដ្ឋទាំងពីរភេទ ត្រូវបំពេញនូវលក្ខខណ្ឌ ដូចខាងក្រោម៖

- ត្រូវបង្ហាញខ្លួននៅចំពោះមុខក្រុមចុះឈ្មោះបោះឆ្នោត នៅការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនត្រូវចុះឈ្មោះបោះឆ្នោត ។
- មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរប្រភេទថ្មី ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ។
- មានសញ្ជាតិខ្មែរ ។
- មានអាយុ ១៨ ឆ្នាំឡើងទៅ គឺកើតមុន ឬកើតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០០៣ ។

– មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវចុះឈ្មោះបោះឆ្នោត ។
– មិនទាន់បានចុះឈ្មោះ ឬបានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេងណាមួយរួចហើយ ឬមិនទាន់បានចុះឈ្មោះនៅកន្លែងណាមួយក្នុងឃុំ សង្កាត់ ។






## ដំណើរប្រព្រឹត្តទៅនៃការចុះឈ្មោះបោះឆ្នោត




នៅពេលបានចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត អ្នកចុះឈ្មោះត្រូវទៅជួបប្រធានក្រុមចុះឈ្មោះបោះឆ្នោតមុនគេ ។ ប្រធានក្រុមចុះឈ្មោះបោះឆ្នោត នឹងសាកសួរអ្នកនូវព័ត៌មានដូចខាងក្រោម ៖

– តើអ្នកមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរប្រភេទថ្មី (អ.ខ) ឬឯកសារបញ្ជាក់អត្តសញ្ញាណ[១] (ឯ.អ) ឬទេ?
– តើអ្នកបានចុះឈ្មោះបោះឆ្នោតហើយ ឬនៅ?

[១] ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតគ្មាន អ.ខ ត្រូវស្នើសុំ ឯ.អ បម្រើឱ្យការចុះឈ្មោះបោះឆ្នោត ។ (នីតិវិធីនៃការស្នើសុំ ឯ.អ សូមមើលទំព័រទី ១៦) ។

បន្ទាប់មកយើងត្រូវ ៖
- ប្រគល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរប្រភេទថ្មី ឱ្យប្រធានក្រុមចុះឈ្មោះ ។
- ប្រាប់ប្រធានក្រុមចុះឈ្មោះថា ខ្ញុំមិនដែលចុះឈ្មោះបោះឆ្នោតទេ ។



- បន្ទាប់មកប្រធានក្រុមចុះឈ្មោះបោះឆ្នោតពិនិត្យភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោតរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត ។




ជួបប្រធានក្រុមចុះឈ្មោះបោះឆ្នោត

- ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតបានបំពេញគ្រប់លក្ខខណ្ឌកំណត់ ប្រធានក្រុមចុះឈ្មោះបោះឆ្នោត នឹងប្រាប់ឱ្យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅជួបអនុប្រធានក្រុមចុះឈ្មោះបោះឆ្នោត ។
- បន្ទាប់មកអនុប្រធានក្រុមចុះឈ្មោះបោះឆ្នោតសួរអ្នកសុំចុះឈ្មោះអំពីទីលំនៅ នៅភូមិណា ដើម្បីគាត់កំណត់បញ្ចូលឈ្មោះក្នុងការិយាល័យបោះឆ្នោតក្នុងភូមិនោះ ។



បន្ទាប់មកអនុប្រធានក្រុមចុះឈ្មោះ
បំពេញទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត( ទ.១០២២ )
រួចប្រគល់ទៅឱ្យការីកុំព្យូទ័រ រួមជាមួយអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
ប្រភេទថ្មី របស់អ្នកសុំចុះឈ្មោះ ។






ជួបអនុប្រធានក្រុមចុះឈ្មោះបោះឆ្នោត

អនុប្រធានក្រុមចុះឈ្មោះត្រូវប្រាប់អ្នកសុំចុះ
ឈ្មោះឱ្យទៅជួបការីកុំព្យូទ័រ ។ ការីកុំព្យូទ័រត្រូវធ្វើតេស្តស្នាមមេដៃ
ទាំងសងខាងរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតជាមុន ហើយបន្ទាប់មកនឹងកត់ត្រា
ទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅក្នុងប្រព័ន្ធកុំព្យូទ័រផ្អែកតាមអត្តសញ្ញាណ
ប័ណ្ណសញ្ជាតិខ្មែរប្រភេទថ្មី និងតាមបង្កាន់ដៃ ទ.១០២២ ។






ជួបការីកុំព្យូទ័រ







ការីកុំព្យូទ័រថតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរប្រភេទថ្មីរបស់អ្នកចុះឈ្មោះបោះឆ្នោត






ការីកុំព្យូទ័រថតរូបអ្នកចុះឈ្មោះបោះឆ្នោត









ការីកុំព្យូទ័រផ្តិតយកស្នាមមេដៃអ្នកសុំចុះឈ្មោះបោះឆ្នោត






អ្នកចុះឈ្មោះបោះឆ្នោតផ្ទៀងផ្ទាត់ទិន្នន័យរបស់ខ្លួន ដែលបង្ហាញនៅលើម៉ូនីទ័រកុំព្យូទ័រ

ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមិនចេះអក្សរ
ឬមើលមិនច្បាស់ គាត់អាចស្នើសុំជំនួយពីអ្នកដទៃបាន
ដើម្បីផ្ទៀងផ្ទាត់ទិន្នន័យរបស់គាត់ ។





អ្នកជំនួយជួយផ្ទៀងផ្ទាត់ទិន្នន័យឱ្យអ្នកចុះឈ្មោះបោះឆ្នោត

ចុងក្រោយ ការីកុំព្យូទ័រប្រគល់បង្កាន់ដៃបញ្ជាក់ការ
ចុះឈ្មោះបោះឆ្នោត (ទ.១០២២) និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
ប្រភេទថ្មីជូនអ្នកសុំចុះឈ្មោះបោះឆ្នោត ជាការស្រេច។





បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរប្រភេទថ្មី



១ ឃើញទេ...អត់ចំណាយពេលយូរទេ!
ចំណាយពេលប្រហែលជា ៥នាទី
ការចុះឈ្មោះបោះឆ្នោតតាមប្រព័ន្ធកុំព្យូទ័រ
អាចរួចជាស្រេច ។

២ អូ!.....ពិតជាងាយស្រួលណាស់!
អ៊ីចឹងខ្ញុំប្រញាប់ទៅចុះឈ្មោះ
បោះឆ្នោតហ្នឹងគេដែរសិន ។



## អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សម្រាប់បម្រើឱ្យការចុះឈ្មោះបោះឆ្នោត




អ.ខ ប្រភេទទី១ អ.ខ ប្រភេទទី២




អ.ខ ប្រភេទថ្មី



## ករណីអាសយដ្ឋានក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ផ្សេងពីលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួន សុំចុះឈ្មោះបោះឆ្នោត




អ.ខ ប្រភេទថ្មី





ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត..........
ក្រុង ស្រុក ខណ្ឌ..........
ឃុំ សង្កាត់..........

លេខ: 000000000

**លិខិតបញ្ជាក់ទីលំនៅ**

យោងប្រកាសលេខ..... ប្រ.ក ចុះថ្ងៃទី.... ខែ...... ឆ្នាំ២០១... របស់ក្រសួងមហាផ្ទៃ ស្តីពីនីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ដោយអាជ្ញាធរឃុំ សង្កាត់ ជូនប្រជាពលរដ្ឋ សម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត។

យើងមេឃុំ ចៅសង្កាត់__________សូមបញ្ជាក់ថា៖
- ឈ្មោះ__________ភេទប្រុស ☐ ស្រី ☐
- កើតនៅថ្ងៃ____ទីខែ____ឆ្នាំ____ ពិតជាមានលំនៅឋានឬទីសំណាក់
- លេខ____ផ្លូវ____ភូមិ____ឃុំ សង្កាត់____
ក្រុង ស្រុក ខណ្ឌ____រាជធានី ខេត្ត____ពិតប្រាកដមែន។

លិខិតបញ្ជាក់ទីលំនៅនេះធ្វើឡើងដោយផ្អែកលើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលមានលេខ__________និងការឆ្លើយបញ្ជាក់របស់សាមីខ្លួន និងសាក្សី៖
- ឈ្មោះ__________ភេទប្រុស ☐ ស្រី ☐
- កើតនៅថ្ងៃទី____ខែ____ឆ្នាំ____មានលំនៅឋានឬទីសំណាក់
លេខ____ផ្លូវ____ភូមិ____ឃុំ សង្កាត់____
ក្រុង ស្រុក ខណ្ឌ____រាជធានី ខេត្ត____
ពិតជាត្រឹមត្រូវ និងទទួលខុសត្រូវចំពោះមុខច្បាប់ ។

លិខិតបញ្ជាក់ទីលំនៅនេះ ចេញជូនសាមីខ្លួន សម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោតតាមការកំណត់នៃច្បាប់បោះឆ្នោត។

ធ្វើនៅថ្ងៃទី.......ខែ.........ឆ្នាំ.........
ស្នាមមេដៃ　　　　មេឃុំ ចៅសង្កាត់
សាមីខ្លួន　　　　សាក្សី



# ករណីគ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ




ប្រសិនបើប្រជាពលរដ្ឋគ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សាមីខ្លួនត្រូវស្នើសុំ ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ត្រូវមកបង្ហាញខ្លួនផ្ទាល់ចំពោះមុខមេឃុំ ឬចៅសង្កាត់ ដោយនាំមកនូវ៖


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Nº XXXXXXX

រាជធានី ខេត្ត ..........
ក្រុង ស្រុក ខណ្ឌ ..........
ឃុំ សង្កាត់ ..........
លេខ ..........

**ឯកសារបញ្ជាក់អត្តសញ្ញាណ**
**បម្រើឱ្យការចុះឈ្មោះបោះឆ្នោត**

រូបថត ៣X៤

យោងលិខិតស្នើសុំរបស់សាមីខ្លួនចុះថ្ងៃទី..........ខែ..........ឆ្នាំ..........
យើងមេឃុំ ចៅសង្កាត់ ☐ ជំទប់/ចៅសង្កាត់រងទទួលសិទ្ធិ ☐ ..........
ចេញឯកសារបញ្ជាក់អត្តសញ្ញាណឱ្យឈ្មោះ..........ភេទ..........សញ្ជាតិ..........
កើតនៅថ្ងៃទី..........ខែ..........ឆ្នាំ..........មានលំនៅឋាន ឬទីសំណាក់លេខ..........ផ្លូវ..........
ភូមិ.......... ក្នុងឃុំ សង្កាត់នេះ ប្រើប្រាស់សម្រាប់បម្រើឱ្យការចុះឈ្មោះបោះឆ្នោតតែប៉ុណ្ណោះ ។
..........ថ្ងៃទី.......... ខែ.......... ឆ្នាំ..........
ហត្ថលេខា ឈ្មោះ និងត្រាឃុំ សង្កាត់

- សំបុត្រកំណើតច្បាប់ដើម ឬសេចក្តីចម្លងសំបុត្រកំណើតច្បាប់ដើម ឬសំបុត្របញ្ជាក់កំណើតច្បាប់ដើម ឬឯកសារផ្សេងទៀតដែលអាចបញ្ជាក់ពីសញ្ជាតិខ្មែរបាន ។
- សាក្សី ២រូប ដែលមានសិទ្ធិបោះឆ្នោត មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ជាមួយ ។
- រូបថត ៣ x ៤ ចំនួន ២ សន្លឹក ។






## ការបិទផ្សាយបញ្ជីឈ្មោះឆ្នោតដំបូង




គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) នឹងបិទផ្សាយជាសាធារណៈនូវបញ្ជីបោះឆ្នោតដំបូង រួមនឹងបញ្ជីឈ្មោះអ្នកដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ នៅសាលាឃុំ សង្កាត់ និងនៅទីតាំងណាមួយក្នុងឃុំ សង្កាត់ ។ ខាងក្រោមនេះ គឺជាគំរូបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត៖



បញ្ជីបោះឆ្នោតដំបូង

លេខកូដរាជធានីខេត្ត: 01 xxxx លេខកូដឃ/ស: 009 ឈ្មោះឃ/ស: xxxx

| ល.រ. | អត្តលេខ | រូបថត | ឈ្មោះ | ភេទ | ថ្ងៃ ខែ ឆ្នាំកំណើត | អាសយដ្ឋាន |
|---|---|---|---|---|---|---|
| ☐1 | 05-001-127 | | ឈ្មោះ: 0103596X1 | ស | 01-04-1980 | អាសយដ្ឋាន |
| ☐2 | 05-001-821 | | ឈ្មោះ: 01055X963 | ប | 03-06-1975 | អាសយដ្ឋាន |
| ☐3 | 05-001-892 | | ឈ្មោះ: 010X22323 | ស | 12-01-1982 | អាសយដ្ឋាន |
| ☐4 | 05-001-848 | | ឈ្មោះ: 010841X03 | ប | 20-08-1985 | អាសយដ្ឋាន |

បញ្ជីបោះឆ្នោតដំបូង



បញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត

លេខកូដរាជធានីខេត្ត 01 xxxx លេខកូដឃ/ស: 009 ឈ្មោះឃ/ស: xxxx

| ល.រ. | អត្តលេខ | រូបថត | ឈ្មោះ | ភេទ | ថ្ងៃ ខែ ឆ្នាំកំណើត | អាសយដ្ឋាន |
|---|---|---|---|---|---|---|
| 1 | 00-006-15 | | ឈ្មោះ: 010X 38961 | ស | 05-11-1970 | អាសយដ្ឋាន |
| 2 | 05-001-821 | | ឈ្មោះ: 0104X5972 | ប | 12-12-1958 | អាសយដ្ឋាន |
| 3 | 05-001-892 | | ឈ្មោះ: 01029202X | ប | 21-02-1967 | អាសយដ្ឋាន |
| 4 | 05-001-848 | | ឈ្មោះ: 0102413X3 | ស | 25-09-1962 | អាសយដ្ឋាន |

បញ្ជីឈ្មោះអ្នកដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត

ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត មានគោលបំណងឱ្យប្រជាពលរដ្ឋអញ្ជើញទៅពិនិត្យផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យផ្សេងៗរបស់គាត់ក្នុងបញ្ជី និងដើម្បីឱ្យប្រជាពលរដ្ឋប្ដឹងតវ៉ា ឬ/និងប្ដឹងជំទាស់ ។






## ការផ្តល់សុពលភាព និងប្រកាសផ្សាយបញ្ជីបោះឆ្នោតផ្លូវការ




គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ផ្តល់សុពលភាព និងប្រកាសផ្សាយបញ្ជីបោះឆ្នោតផ្លូវការ**នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០** ។

គ.ជ.ប នឹងបញ្ជូនបញ្ជីបោះឆ្នោតផ្លូវការទៅសាលាឃុំ សង្កាត់ ១ (មួយ)ច្បាប់ និងទៅលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) ១ (មួយ)ច្បាប់ ដើម្បីរក្សាទុកជាឯកសារផ្លូវការ ។

